# ៥. ធ្វើឱ្យការអប់រំអាចទទួលយកបាន

គេតែងសង្កេតឃើញមានការយកចិត្តទុកដាក់មិនបានជិតដល់លើវិស័យអប់រំពីជំនាន់មួយទៅជំនាន់មួយទៀត ហើយការធ្វើបែបនេះគឺជាការបង្កឲ្យភាពគ្រីក្រចេះតែបន្តឥតឈប់។ បាតុភូតបែបនេះត្រូវបានចងក្រងជាឯកសារយ៉ាងច្រើនសំបូរបែប។ គេក៏បានដឹងច្បាស់គ្រប់ៗគ្នាដែរថា វ័យដំបូងនៃកុមារភាពគឺជាដំណាក់កាលយ៉ាងសំខាន់នៃការអភិវឌ្ឍន៏បញ្ញា ស្មារតីក្នុងការរៀនសូត្រ។ ក្របខ័ណ្ឌសកម្មភាពក្រុងដាកាផ្តល់អាទិភាពសំរាប់អភិវឌ្ឍសក្តានុភាពនៃសមត្ថភាពរបស់កុមារទាំងអស់ក្នុងការសិក្សាដោយកំណត់គោលដៅដើម្បីសំរេចការអប់រំសំរាប់ទាំងអស់គ្នាឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

### ៥.១. វិភាគអំពីដំណើរការការរៀន និងបង្រៀនទាំងស្រុង

លទ្ធផលដែលបានគិតទុកមុននៃដំណើរការរៀនសូត្រហាក់ដូចជាច្រើនតែឆ្លុះបញ្ចាំងអំពីការកំណត់និយមន័យគុណភាពដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ។ បើនិយាយតាមការអប់រំដោយផ្អែកលើសិទ្ធិមនុស្ស សំរាប់ខ្នាតគំរូសិទ្ធិមនុស្សនេះ ក្រមខ័ណ្ឌសកម្មភាពរួមដែលមាន *ធនធាន–ដំណើរការ–លទ្ធផល* ចាំបាច់ត្រូវបន្ថែម *ការចុះឈ្មោះ និងលទ្ធផលរំពឹងសំរេចបានក្នុងរយ:ពេលយូរអង្វែងថែមទៀត*។ នៅពេលនោះក្របខ័ណ្ឌនោះនឹងក្លាយទៅជា *ការចុះឈ្មោះចូលរៀន–ការដាក់ធនធាន–ដំណើរការបង្រៀន–លទ្ធផល–លទ្ធផលរំពឹងសំរេចបានក្នុងរយ:ពេលយូរអង្វែង*។ ប៉ុន្តែគេត្រូវកត់សំគាល់ថា សន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្សមិនបានកំណត់និយមន័យនៃគុណភាពអប់រំទេ។ នេះគឺជាបញ្ហាដែលបន្សល់ទុកសំរាប់អ្នកអប់រំ និងចំណុចដាក់លាក់ពិស្តារមានបញ្ជាក់នៅក្នុងច្បាប់អប់រំក្នុងប្រទេសនីមួយៗ។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិកំណត់តួនាទីដែលការអប់រំត្រូវបំពេញ (ដូចជាការលុបបំបាត់ការរើសអើង ដូចមានបញ្ជាក់នៅក្នុងតារាងលេខ៩) និងគោលដៅដែលការអប់រំត្រូវសំរេចឲ្យបាន (មើលតារាងលេខ ២)។

សូចនាករណ៍ត្រូវបានបង្កើតឡើងដើម្បីតាមដានការអប់រំដោយផ្អែកលើទស្សនៈសិទ្ធិមនុស្ស និងចៀសមិនផុតទេថា ប្រទេសនីមួយៗស្ថិតក្នុងដំណាក់កាលនៃការរីកចំរើនខុសៗគ្នា។ ភាពខុសគ្នានៅក្នុងប្រទេស និងរវាងប្រទេសបង្ហាញពីកង្វះខាតសាលាដែលមានសុវត្ថិភាព និងបរិស្ថានល្អ និងខ្វះគ្រូដែលមានការបណ្តុះបណ្តាលគរុកោសល្យត្រឹមត្រូវ។

ភារកិច្ចរបស់រដ្ឋាភិបាលដើម្បីកំណត់ និងពង្រឹងស្តង់ដាអប់រំទាមទារឲ្យមានការវាយតម្លៃស្ថានភាពអប់រំបច្ចុប្បន្នឲ្យបានត្រឹមត្រូវតាមបរិការទិសដៅអន្តរជាតិ។ ស្តង់ដាដែលត្រូវបង្កើតត្រូវអនុវត្តឲ្យបានដូចគ្នានៅគ្រប់កន្លែង។ ស្ថាប័ន និងនីតិវិធីត្រូវតែកំណត់ឲ្យបានច្បាស់លាស់សំរាប់អនុវត្ត តាមដាន និងពង្រឹងស្តង់ដាទាំងនេះ។ ជាការពិតណាស់ គ្មានប្រព័ន្ធអប់រំណាដែលអាចអភិវឌ្ឍសក្តានុភាពរបស់កុមារឲ្យបានពេញលេញនោះទេ ប្រសិនជាប្រព័ន្ធអប់រំនោះពុំមានឧបករណ៍គ្រប់គ្រាន់ បរិស្ថានពុំមានសុវត្ថិភាព ហើយគ្រូពុំមានការបណ្តុះបណ្តាលត្រឹមត្រូវ។ ប្រហែលគ្នានេះដែរ ការលុបបំបាត់ចោលការរើសអើងមិនអាចសំរេចបានតាមរយ:ការអប់រំបានទេ ប្រសិនជាកុមារជនជាតិភាគតិច និងជនជាតិដើមបានចូលរៀនតែនៅក្នុងសាលាដែលពុំមានគុណភាព។

ចំណាប់អារម្មណ៏នៃសិទ្ធិមនុស្សក្នុងវិស័យអប់រំស្ថិតនៅលើអ្នករៀនសូត្រ ជាពិសេសកុមារ ហើយចំណុចសំខាន់នៃវិធីនេះគឺនិរន្តរភាព។ ការងារនេះបានសំរេចរួចហើយ ដូចដែលបានបញ្ជាក់ពីខាងដើម ដោយការ កំណត់សិទ្ធិនៃការទទួលបានរបស់កុមារដូចដែលបានកំណត់ក្នុងកាតព្វកិច្ចរបស់រដ្ឋាភិបាល។ គម្រោងនីមួយៗរបស់អ្នកផ្តល់ជំនួយអន្តរជាតិ ឬអង្គការក្រៅរដ្ឋាភិបាលអាចមានសារប្រយោជន៏សំរាប់ក្រុមកុមារណាមួយ ក៏ប៉ុន្តែផលប្រយោជន៏ដ៏ធំធេងរបស់អង្គការនេះត្រូវបាត់បង់ទៅវិញបន្ទាប់ពីគម្រោងរបស់គេបញ្ចប់។

ជាងនេះទៀត ការពិតបង្ហាញថា មានកុមារមួយចំនួនបានទទួលផលប្រយោជន៍ពីកម្មវិធីនានា នៅពេល ដែលកុមារមួយចំនួនទៀតត្រូវបានគេធ្វើមិនដឹងមិនឮ ដែលតាមពិត កុមារទាំងនោះគួរទទួលបានសិទ្ធិដូចគ្នា។ គម្រោងដែលបានរៀបចំហើយ និងសម្ភារដែលមានលក្ខណៈងាយស្រួលប្រើសំរាប់កុមារ ឬការបង្រៀនដោយប្រើ វិធីសិស្សមជ្ឈមណ្ឌលអាចផ្តល់នូវសារប្រយោជន៍យ៉ាងច្រើន នៅពេលដែលកុមារទទួលបានចម្លើយ និងដំណោះស្រាយពីរដ្ឋាភិបាលអំពីកង្វះការអប់រំ។ លក្ខណៈអំណោយផលបែបនេះគួរតែរក្សាឲ្យបាន និងពង្រីកវិសាលភាពរបស់វាតាមពេលវេលាសមស្រប។

ហេតុដូច្នេះហើយបានជាគេសង្កេតឃើញមានការផ្លាស់ប្តូរយុទ្ធវិធីនៃកិច្ចសហប្រតិបត្តិការអន្តរជាតិទៅជាយុទ្ធវិធីនៃការរួមបញ្ចូលទូទាំងវិស័យវិញ។ បំរែបំរួលនេះទាក់ទងនឹងការបង្កើតយុទ្ធសាស្ត្រអប់រំដែលមានរដ្ឋាភិបាលជាអ្នកនាំមុខ និងទទួលការគាំទ្រពីខាងក្រៅ។ ការបញ្ចូលសិទ្ធិមនុស្សឲ្យបានពេញលេញទៅក្នុងយុទ្ធវិធីទូទាំងវិស័យនឹងផ្តល់ជាគំរូដ៏ល្អបំផុតសំរាប់ធ្វើឲ្យមាននិរន្តរភាព និងពង្រីកផលប្រយោជន៍ដែលបានមកពីគម្រោង ឬកម្មវិធីពិសេសណាមួយ។

**ផលប្រយោជន៍ដ៏ប្រសើរបំផុតរបស់កុមារម្នាក់ៗ**

គោលការណ៍គន្លឹះរបស់កតិកាសញ្ញាស្តីពីសិទ្ធិកុមារ ដែលបញ្ជាក់យ៉ាងច្បាស់ថា ការអប់រំត្រូវតែរៀបចំ និងអនុវត្តដោយចាត់ទុកផលប្រយោជន៍សំរាប់កុមារធំជាងគេ។ ធ្វើបែបនេះបាន ចាំបាច់ត្រូវមានការកំណត់សំគាល់ និងលុបបំបាត់ចោលកត្តាទាំងឡាយដែលរារាំងដល់ដំណើរការរៀនសូត្ររបស់កុមារ។ ឧបសគ្គទាំងនេះរួមមានការប្រើប្រាស់ភាសាជាយានសំរាប់ការបង្រៀន ដែលមិនមែនជាភាសាកំណើតរបស់កុមារ ឬកម្មវិធីសិក្សាដែលមិនសមនឹងអាយុរបស់កុមារ។ ដូច្នេះ ចាំបាច់ត្រូវកត់សំគាល់ និងកត់ត្រារាល់ទិន្នន័យរបស់កុមារ ដែលទាក់ទងទៅនឹងដំណើរការរៀន និងបង្រៀនចាប់តាំងពីកុមារមកចុះឈ្មោះចូលរៀនពីដំបូង។

ដំណាក់កាលផ្លាស់ប្តូរនៃការចាកចេញពីការអប់រំទៅក្នុងសង្គមក៏ទាមទារឲ្យមានការតាមដានដោយផ្អែកលើលក្ខណៈវិនិច្ឆ័យសិទ្ធិមនុស្សផងដែរ។ នៅកន្លែងដែលលទ្ធផលនៃការសិក្សាទទួលបានគួរជាទីពេញចិត្តតែអ្នកបញ្ចប់ការសិក្សាបែរជាគ្មានការងារធ្វើ ដូច្នេះ តម្រូវការទំនាក់ទំនងរវាងផ្នែកផ្សេងៗនឹងត្រូវមើលឃើញយ៉ាងច្បាស់។ គោលការណ៍នៃភាពមិនអាចបំបែកបានរបស់សិទ្ធិមនុស្សទាមទារឲ្យមានការសម្របសម្រួលរវាងគោលនយោបាយអប់រំ និងគោលនយោបាយការងារ។ បញ្ហាទាំងអស់នេះមាននិយាយយ៉ាងច្បាស់នៅក្នុងផ្នែកនៃការកែប្រែការអប់រំតាមតម្រូវការជាក់ស្តែង។

ចក្ខុវិស័យនៃសិទ្ធិមនុស្សពង្រីកចំណាប់អារម្មណ៍ទូទៅលើទិន្នន័យបរិវិស័យដើម្បីបញ្ចូលសិទ្ធិទាំងអស់របស់តួអង្គសំខាន់ៗនៅក្នុងវិស័យអប់រំ។ ដូចដែលយូណេស្កូបានថែងថា "ការបញ្ចូលសិទ្ធិមនុស្សទៅក្នុងការអប់រំគឺជាធាតុសំខាន់ដែលនាំឲ្យការអប់រំមានគុណភាពខ្ពស់"។[២៦] អនុសាសន៍នេះតម្រូវឲ្យមានការកែប្រែយុទ្ធសាស្ត្រអប់រំមួយចំនួនដែលអាចស៊ីគ្នានឹងស្តង់ដាសិទ្ធិមនុស្សសកលអប្បបរមា ដែលមានគ្រប់តួអង្គសំខាន់ៗ ដូចជាអ្នករៀន ឪពុកម្តាយ និងគ្រូបង្រៀន។ ការងារនេះតម្រូវឲ្យមានទិន្នន័យគុណវិស័យផង និងបរិវិស័យផងដែលទិន្នន័យទាំងនេះមិនទាន់មាននៅឡើយ ពីព្រោះដំណើរការនៃការបញ្ចូលសិទ្ធិមនុស្សទៅក្នុងប្រព័ន្ធអប់រំទាំងមូលគឺស្ថិតនៅ ក្នុងដំណាក់កាលដំបូងនៅឡើយ។ តារាងលេខ ៩ បង្ហាញពីក្របខ័ណ្ឌ ៥ យ៉ាង ដែលបញ្ជាក់ពីបញ្ហាទាក់ទងនឹងសិទ្ធិមនុស្ស និងគុណភាពអប់រំ។

26. UNESCO Executive Board - Elements for an overall UNESCO strategy on human rights, Doc. 165 EX/10 (2002), para. 31.

## តារាង ១០ : តារាងម៉ាទ្រីកផ្អែកលើសិទ្ធិដើម្បីគុណភាពអប់រំ

| កត្តាគន្លឹះ | បញ្ហាដែលលើកឡើងដោយនិយាមសិទ្ធិមនុស្សនានា |
| --- | --- |
| ***ចុះឈ្មោះចូលរៀន*** | តើសិទ្ធិរបស់កុមារគ្រប់រូបដើម្បីចុះបញ្ជីកំណើតត្រូវបានគេធានាដោយពេញលេញឬទេ? ប្រសិនជាមិនមានទេ តើគេបានចាត់វិធានការអ្វីខ្លះដើម្បីបំពេញចំណុចខ្វះខាតនេះ? តើការធ្វើជំរឿននៃកុមារគ្រប់អាយុចូលរៀនបានទាំងអស់ និងមានប្រសិទ្ធភាពឬទេ? ប្រសិនជាគេមានព័ត៌មានស្តីពីកុមារដែលមិនត្រូវបានបញ្ចូល ឬកុមារដែលស្ថិតនៅទីដាច់ស្រយាល តើបានចាត់វិធានការអ្វីខ្លះដើម្បីបញ្ចប់នូវគម្លាតគ្នានៃការផ្តល់ការអប់រំដោយកាតព្វកិច្ចសំរាប់កុមារគ្រប់រូប? តើព័ត៌មានស្ថិតិបញ្ចូលនូវការហាមឃាត់អន្តរជាតិស្តីពីការរើសអើងទាក់ទងនឹងកុមារ និងឪពុកម្តាយ (*សញ្ជាតិ ពណ៌សម្បុរ ភេទ ភាសា សាសនា ទស្សនៈនយោបាយ ទីកន្លែងកំណើត ស្ថានភាពសេដ្ឋកិច្ច វណ្ណៈសង្គម ជនជាតិភាគតិច ជនជាតិដើម ពិការភាព*)? បើគ្មានទេ តើផែនការនៃការអភិវឌ្ឍន៍ព័ត៌មានស្ថិតិអប់រំនឹងបញ្ចូលនូវចំណុចនៃការហាមឃាត់មិនឲ្យមានការរើសអើងជាលក្ខណៈ អន្តរជាតិនេះឬទេ?<br><br>តើទិន្នន័យអ្វីខ្លះដែលគេបានកត់ត្រាសំរាប់កុមារដែលបានចុះឈ្មោះចូលរៀន? តើនីតិវិធីតម្រូវឲ្យមានលិខិតបញ្ជាក់អ្វីខ្លះ (ដូចជា សំបុត្រកំណើត សញ្ជាតិ ឬទីលំនៅ)? តើគេដឹងអ្វីខ្លះពីស្ថានភាពគ្រួសាររបស់សិស្ស? តើមានការធានាយ៉ាងណាខ្លះទាក់ទងនឹងសេរីភាពក្នុងការជ្រើសរើសរបស់ឪពុកម្តាយក្នុងការបញ្ជូនកូនទៅរៀន? តើមានវិធានការដាក់ស្តែងអ្វីខ្លះដើម្បីធានាផ្តល់ការអប់រំដល់កុមារដែលគ្រួសារបោះបង់ចោល? |
| ***កាដាក់ធនធាន*** | តើមានការធានាជាតាមផ្លូវច្បាប់ដែលថា ការបែងចែកថវិកាសំរាប់ការអប់រំដោយកាតព្វកិច្ចត្រូវស្របនឹងតម្លៃប៉ាន់ប្រមាណសំរាប់គុណភាពនៃការអប់រំសំរាប់កុមារទាំងអស់គ្នាឬទេ? បើដូច្នេះមែន តើមានយន្តការ ស្ថាប័ន (ដូចជាតុលាការ ឬស្នងការសិទ្ធិមនុស្ស) ដើម្បីផ្តល់បន្ថែមនូវរាល់ថវិកាដែលបានបែងចែកឬខ្វះខាតដែរឬទេ? បើមិនមានទេ តើផែនការជាតិដើម្បីធានាការអប់រំដោយកាតព្វកិច្ចសំរាប់កុមារគ្រប់រូបត្រូវបានបង្កើតឡើងហើយឬនៅ? ប្រសិនជាទំនួលខុសត្រូវហិរញ្ញវត្ថុសំរាប់ការអប់រំដោយកាតព្វកិច្ចត្រូវបានធ្វើឲ្យទៅជាវិមជ្ឈការ តើទំនួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋានបានទទួលធនធានដោយមានការធានាត្រឹមត្រូវគ្រប់គ្រាន់ឬទេ? ជាមួយនឹង ការបែងចែកថវិកា តើធនធានផ្សេងទៀតនៅក្នុងវិស័យអប់រំត្រូវបានកំណត់ឲ្យច្បាស់ថានឹងទទួលបានដូចរដ្ឋាភិបាល ឬស្ថាប័នសាធារណៈផ្សេងទៀតដែរឬទេ? |
| ***សកម្មភាពបង្រៀន–រៀន*** | **ការបង្រៀន** : តើការចូលរួមរបស់គ្រូនៅក្នុងការបង្កើតគោលនយោបាយ និងច្បាប់អប់រំត្រូវបានគេធានាឬទេ? តើសិទ្ធិពលរដ្ឋ និងវិជ្ជាជីវៈរបស់គ្រូ និង សេរីភាពក្នុងការបង្កើតសមាគមត្រូវបានគេធានាតាមបទដ្ឋានសកលឬទេ? តើវិធានការត្រូវបានគេធ្វើឲ្យស៊ីគ្នានូវប្រវត្តិរបស់គ្រូឬទេ (ទាក់ទងនឹង ភេទ សញ្ជាតិ ភាសា។ ល។) ទៅនឹងប្រវត្តិរបស់សិស្សឬទេ? តើខ្លឹមសារ និងវិធីសាស្ត្របង្រៀន ត្រូវបានគេវាយតម្លៃឲ្យបានត្រឹមត្រូវដោយប្រើខ្នាត សិទ្ធិមនុស្សឬទេ? តើការបណ្តុះបណ្តាលគ្រូមានបញ្ចូលការអប់រំសិទ្ធមនុស្ស ឬទេ?<br><br>**ការសិក្សា** : តើយុទ្ធសាស្ត្រនៃការអប់រំឆ្លើយតបទៅនឹងតម្រូវការសំរាប់ឲ្យ កុមារម្នាក់ធ្វើការសម្របសម្រួលឬទេ? បើមិនទេ តើវិធានការអ្វីដែលគេបានយកមកអនុវត្តដាក់ស្តែងដើម្បីបង្កើតឲ្យមានការសម្របសម្រួលនេះ? តើគេវាយតម្លៃ និងកត់ត្រាសមត្ថភាព និងពិការភាពរបស់សិស្សដោយរបៀបណា? តើគេធ្វើការវាយតម្លៃឧបសគ្គនៃការសិក្សារបស់សិស្សជាបន្តបន្ទាប់ដោយរបៀបណា ដើម្បីជួយឲ្យពួកគេអាចជំនះឧបសគ្គទាំងនោះបាន? តើវិធីសាស្ត្រអ្វីខ្លះដែលគេបានយកមកអនុវត្តក្នុងការអប់រំដោយប្រើប្រាស់ភាសាកំណើតរបស់កុមារ? |
| ***លទ្ធផល*** | តើការវាយតម្លៃកម្មវិធីសិក្សាចុងក្រោយត្រូវបានគេធ្វើឡើងនៅពេលណា និងមានការកែប្រែអ្វីខ្លះ? តើគេផ្តល់អាទិភាពលើលទ្ធផលសិក្សាអ្វីខ្លះ ហេតុអ្វី? តើដំណើរការនៃការវាយតម្លៃលទ្ធផលសិក្សាសមស្របទៅនឹងសមត្ថភាព និងកាលានុប្បវត្តភាពរបស់កុមារយ៉ាងដូចម្តេច? តើវិធីណាដែលគេយកមកអនុវត្តដើម្បីវាយតម្លៃលទ្ធផលសិក្សាទាក់ទងទៅនឹងការអប់រំសិទ្ធិមនុស្ស? |
| ***លទ្ធផលចុងក្រោយ*** | តើគេបានវិភាគកម្មវិធីអប់រំដោយផ្អែកលើតម្រូវការសិទ្ធិមនុស្សឬទេ? តើវត្ថុបំណងខាងក្រៅ (ដូចជា កាត់បន្ថយភាពក្រីក្រ សមភាពយេនឌ័រ ឬវណ្ណៈសង្គម) ត្រូវបានគេតាមដានពិនិត្យដោយរបៀបណា? បើមានអ្នកបញ្ចប់ការសិក្សាហើយ តែគ្មានការងារធ្វើ តើគេបានចាត់វិធានការអ្វីខ្លះដើម្បីធ្វើឲ្យការអប់រំ និងការងារស៊ីចង្វាក់គ្នា? តើវិធីសាស្ត្រខ្លះដែលគេបានអនុវត្តដើម្បីធានាឲ្យមានសមភាពយេនឌ័រគិតជាតួលេខនៅក្នុងការអប់រំ? តើផលប៉ះពាល់នៃការអប់រំលើការ រីកចំរើនឆ្ពោះទៅរកសមភាពយេនឌ័រ និងអនុសាសន៍ត្រូវបានគេតាមដានពិនិត្យឬទេ? |

## ៥.២. ទំនាក់ទំនងរវាងការចុះឈ្មោះ និងធនធាន

ព័ត៌មានស្ថិតិអប់រំហាក់ដូចជារាប់បញ្ចូលតែកុមារដែលគ្រប់អាយុចូលរៀនប៉ុណ្ណោះ ដោយគិតតាមអាយុ និងភេទ។ វិធីសាស្ត្រផ្អែកលើសិទ្ធិកុមារមានទ្រង់ទ្រាយធំជាងនេះ ហើយតម្រូវឲ្យមានការកត់សំគាល់ឧបសគ្គនានាដែលរារាំងកុមារមិនឲ្យចូលរៀន។ នៅកំរិតម៉ាក្រូ ការកត់សំគាល់ និងគុណគួរអំពីឧបសគ្គនានានៃការអប់រំរបស់កុមារត្រូវបញ្ចូលព័ត៌មានស្ថិតិទាំងអស់។ ដូច្នេះ ការរៀបចំគម្រោងដើម្បីប្រមូលព័ត៌មានស្ថិតិទាក់ទងនឹងបញ្ហាសិទ្ធិមនុស្សគឺជាកត្តាសំខាន់មិនអាចខ្វះបាន។

ទិន្នន័យបីវិស័យត្រូវបញ្ចូលប្រវត្តិជនជាតិ និងសាសនារបស់កុមារ។ អត្តសញ្ញាណបុគ្គល ដូចជាសញ្ជាតិ ឬសាសនាត្រូវបានហាមឃាត់នៅក្នុងប្រទេសជាច្រើន ដូច្នេះទិន្នន័យផ្អែកលើប្រជាពលរដ្ឋត្រូវបានប្រើប្រាស់ជំនួសវិញ។ ការកត់ត្រាសាសនា និងគណបក្សនយោបាយរបស់ឪពុកម្តាយ និងកូនគឺជាទង្វើគួរឲ្យបារម្ភពីព្រោះគ្រួសារជាច្រើនអាចក្លាយជាជនរងគ្រោះដោយសារតែបញ្ហាសាសនា និងនយោបាយ។ ឧទាហរណ៍ នៅប្រទេសឥណ្ឌូណេស៊ី ការប្រមូលទិន្នន័យផ្លូវការទាក់ទងនឹងសាសនាបង្កឲ្យមានភាពចំរុងចំរាស់យ៉ាងខ្លាំង។[២៧]

យុទ្ធសាស្ត្រអប់រំ ទិន្នន័យបរិវិស័យគួរតែបញ្ចូលបញ្ហាសិទ្ធិមនុស្សដែលទទួលស្គាល់ជាផ្លូវការនូវភាពសម្បូរបែបនៃសាសនា និងគណបក្សនយោបាយនៅក្នុងសង្គមដើម្បីកុំឲ្យមានការរើសអើង និងបង្កឲ្យមានគ្រោះថ្នាក់ដោយសារការរើសអើងទាំងនេះ។

ដំណើរការនៃការកត់សំគាល់សមត្ថភាពសិក្សា និងពិការភាពរបស់សិស្សក៏បង្កឲ្យមានការចំរុងចំរាស់គ្នាយ៉ាងខ្លាំងផងដែរ ទោះបីជាមានលក្ខណៈខុសគ្នាបន្តិចបន្តួចក៏ដោយ។ កិច្ចខិតខំប្រឹងប្រែងបន្តបន្ទាប់ដើម្បីប្រមូលព័ត៌មានស្ថិតិដែលអាចប្រៀបធៀបគ្នាជាលក្ខណៈអន្តរជាតិទាក់ទងនឹងពិការភាព (តម្រូវការពិសេស) បង្ហាញពីភាពខុសគ្នាក្នុងការកំណត់និយមន័យ។ ចំនួនកុមារដែលគេចាត់ទុកថា ទាមទារឲ្យមានតម្រូវការ ពិសេសមានចាប់តាំងពី ១ ភាគរយនៅក្នុងប្រទេសមួយចំនួន និង ៤១ ភាគរយនៅក្នុងប្រទេសមួយចំនួនទៀត។ ភាពខុសគ្នានេះបង្ហាញពីការកំណត់និយមន័យខុសគ្នាទាក់ទងនឹងពិការភាព ការលំបាក និងគុណវិបត្តិ។[២៨]

ធានាថា ភាពខុសគ្នានៅក្នុងការចុះឈ្មោះរបស់សិស្សដែលត្រូវតែស៊ីគ្នាទៅនឹងធនធាននៅក្នុងដំណើរការបង្រៀន និងរៀននៅតែជាបញ្ហាដែលមិនទាន់សំរេចបានសំរាប់កុមារជាច្រើន។ វិស័យអប់រំនៅតែទទួលបានថវិកាតិចជាងចំនួនដែលគួរទទួលបានដើម្បីធានាអនុវត្តការអប់រំសំរាប់ទាំងអស់គ្នាឲ្យបានសំរេច។ ហេតុផលសំខាន់គឺថា ការបែងចែកថវិកានៅក្នុងប្រទេសភាគច្រើនធ្វើឡើងដោយពុំមានការចូលរួមពីច្រើនភាគីទេ។ ដើម្បីប្រែក្លាយសិទ្ធិទទួលការអប់រំឲ្យក្លាយទៅជាការពិត ចាំបាច់ត្រូវមានការធានាច្បាស់លាស់ទាក់ទងនឹងការបែងចែកធនធានរបស់រដ្ឋ ដូចជាក្នុងប្រទេសខ្លះដែលបានកំណត់ថា ២៥ភាគរយ ឬ៦ ភាគរយនៃ GNP ត្រូវតែចំណាយលើវិស័យអប់រំ។ អត្ថបទខាងក្រោមបង្ហាញពីបំរែបំរួលថ្មីៗនៅប្រទេសឥណ្ឌូណេស៊ីទាក់ទងនឹងការចំណាយលើវិសយអប់រំ។។

"ការអភិវឌ្ឍន៏មួយក្នុងចំណោមការអភិវឌ្ឍន៏នានាដែលបានកត់ត្រានៅក្នុងកំណែទម្រង់ប្រព័ន្ធអប់រំរបស់ប្រទេសឥណ្ឌូណេស៊ីគឺជាការធ្វើវិសោធនកម្មទី៤នៃរដ្ឋធម្មនុញ្ញ នៅថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០២។

*27. Commission on Human Rights – Report of the Special Rapporteur on the right to education on her mission to Indonesia, E/CN.4/2003/9/Add, 1, para. 27.*

*28. Commission on Human Right – Annual report of the Special Rapporteur on the right to education, E/CN/2002/60, paras, 43-45.*

រដ្ឋធម្មនុញ្ញដែលត្រូវធ្វើវិសោធនកម្មថ្មីៗមិនត្រឹមតែធានាផ្តល់សិទ្ធិអប់រំចំពោះជនជាតិឥណ្ឌូណេស៊ីគ្រប់រូបប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឆ្លើយតបទៅនឹងកាតព្វកិច្ចរបស់រដ្ឋទៀតផង។ មាត្រាទី ៣១ បញ្ជាក់អំពីកាតព្វកិច្ចរបស់រដ្ឋាភិបាលក្នុងការធានាបំពេញឲ្យបាននូវសិទ្ធិពលរដ្ឋក្នុងការទទួលការអប់រំមូលដ្ឋាន ក៏ដូចជាទំនួលខុសត្រូវលើបញ្ហាហិរញ្ញវត្ថុផងដែរ។ លើសពីនេះទៀត រដ្ឋត្រូវអភិវឌ្ឍ និងអនុវត្តប្រព័ន្ធអប់រំជាតិ និងបំរុងថវិកាយ៉ាងហោចណាស់ ២០ ភាគរយនៃថវិការដ្ឋបាលមូលដ្ឋានដើម្បីបំពេញតម្រូវការអប់រំនេះផងដែរ។[២៩]

ច្បាប់បែបនេះធានាឲ្យមានការប្តេជ្ញាខាងផ្នែកហិរញ្ញវត្ថុដែលត្រូវចំណាយលើគ្រប់ផ្នែកទាំងអស់នៃវិស័យអប់រំ។ ជាញឹកញាប់ ការបែងចែកថវិកាបង្ខំឲ្យអាជ្ញាធរអប់រំផ្តល់ថវិកាមិនគ្រប់គ្រាន់ក្នុងចំណោមកម្មវិធីមូលដ្ឋាន និងកម្មវិធីជាតិនៅពេលដែលថវិកាមិនគ្រប់គ្រាន់សំរាប់ផ្នែកណាមួយ។ ដូច្នេះ ទំនាក់ទំនងរបស់សិទ្ធិកុមារក្នុងការទទួលការអប់រំដែលមានគុណភាព និងកាតព្វកិច្ចរបស់រដ្ឋាភិបាលក្នុងការធានាផ្តល់ហិរញ្ញវត្ថុគឺជាដំណាក់កាលដំបូងដ៏សំខាន់។ ចំណុចសំខាន់មួយទៀតគឺ ការប្រៀបធៀបធនធាននៅកំរិតម៉ាក្រូ – គឺថា តម្រូវការ និងបុគ្គលិកលក្ខណៈរបស់កុមារដែលចូលរៀននៅបឋមសិក្សា និងដំណើរការនៃការបង្រៀននិងរៀននៅកំរិតមីក្រូ។ ភាពមិនស៊ីចង្វាក់គ្នាអាចមានយ៉ាងច្បាស់នៅក្នុងការចុះឈ្មោះចូលរៀន និងការដាក់ធនធានសំរាប់ការអប់រំ ប៉ុន្តែបញ្ហាទាំងនេះមិនទទួលបានការយកចិត្តទុកដាក់ដើម្បីធ្វើយ៉ាងណាឲ្យឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកសិក្សាបានទេ។

### ៥.៣. ការមិនយកចិត្តទុកដាក់លើសិទ្ធិរបស់គ្រូបង្រៀន

យុទ្ធសាស្ត្រអប់រំនានាហាក់ដូចជាផ្តល់អាទិភាពលើការសិក្សា សង្កត់ធ្ងន់លើអត្ថប្រយោជន៏នៃខ្លឹមសារអប់រំសំរាប់សិស្ស និងដំណើរការរៀនសូត្រដោយប្រើវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល។ ការបង្រៀនវិញមានការចាប់អារម្មណ៍តិចតួចណាស់ ដូចជា សិទ្ធិរបស់គ្រូដែលមានការធានាជាលក្ខណៈអន្តរជាតិក៏ដោយ។ *ឧទាហរណ៏នៅប្រទេសកម្ពុជា "គ្រូមានជីវភាពរស់នៅទាបបំផុត។ ដោយហេតុនេះ ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយជាការងារដែលមិនអាចធ្វើទៅបាន។ លើសពីនេះទៀត គ្រូមួយចំនួនត្រូវបង្ខំចិត្តប្រកបមុខរបរមួយផ្សេងទៀតដូចជា រត់ម៉ូតូឌុប ឬធ្វើស្រែចំការដើម្បីទ្រទ្រង់ជីវភាពគ្រួសារ"*[៣០]។

ការស្វែងយល់ពីជោគវាសនារបស់គ្រូបង្រៀនជាច្រើនបង្ហាញឲ្យឃើញថា ទាំងសិទ្ធិពលកម្មរបស់គ្រូ និង សេរីភាពសហជីពរបស់គ្រូបង្រៀនមិនត្រូវបានគេទទួលស្គាល់ពេញលេញទេ។ ចំណុចទាំងពីរនេះគឺជាបទដ្ឋានសំខាន់នៃបទដ្ឋានពលកម្មអន្តរជាតិ។ បទដ្ឋានទាំងពីរនេះត្រូវបានពង្រឹងនៅក្នុងប្រទេសជាច្រើន និងទទួលបានការគាំទ្រពីធនាគារអភិវឌ្ឍន៏អាស៊ី។ ទន្ទឹមនឹងនីតិវិធីធ្វើរបាយការណ៏ និងការប្តឹងផ្តល់នៅក្នុងអង្គការពលកម្មពិភពលោក គណៈកម្មាធិការនៃក្រុមជំនាញការរបស់អង្គការពលកម្មពិភពលោក និងយូណេស្កូទទួលបន្ទុកការអនុវត្តតាមអនុសាសន៏ទាក់ទងនឹងឋានៈរបស់គ្រូបង្រៀនតែងជួបគ្នាជារាល់ ៣ ឆ្នាំម្តង ដើម្បីតាមដាន ត្រួតពិនិត្យលើការអនុវត្តន៏តាមអនុសាសន៏ និងដើម្បីធ្វើការស៊ើបអង្កេតទៅលើការរំលោភបំពានអនុសាសន៏ទាំងនេះ។ ការតាមដាន ត្រួតពិនិត្យនេះអាចធ្វើលើបញ្ហាជាច្រើន រួមបញ្ចូលទាំងប្រាក់ខែគ្រូ សុវត្ថិភាពការងារ លក្ខខណ្ឌការងារ សិទ្ធិទទួលបានសុវត្ថិភាពសង្គម ការរើសអើងប្រឆាំងគ្រូបង្រៀន ស្ថានភាពការងាររបស់គ្រូ "ជាប់កិច្ចសន្យា"។

---

29 *Statement by Indonesian delegation before the 59th session of the Commission on Human Rights, Geneva, 3 April 2003, on the report of the Special Rapporteur on the right to education on her mission to Indonesia in July 2002.*

30 *Initial report of Cambodia under the Convention on the Rights of the Child, CRC/C?11/Add. 16, 1998.*

**ស្ថានភាព និងឋានៈរបស់ គ្រូបង្រៀន**

ជាញឹកញាប់ គ្រូនៅមធ្យមសិក្សាបំពេញការងារជាបុគ្គលិករដ្ឋ ដោយសារហេតុផលនេះ ទើបសិទ្ធិបង្កើតសហជីពគ្រូបង្រៀនត្រូវបានបដិសេធ។ ដោយសារ ធ្វើជាគ្រូបង្រៀនគឺជាមុខងារសំខាន់ខ្លាំងនៅក្នុងរដ្ឋាភិបាល ទើបគ្រូបង្រៀនពុំមានសិទ្ធិធ្វើបាតុកម្ម។ គណៈកម្មាធិការសមាគមដើម្បីសេរីភាពរបស់អង្គការពលកម្មពិភពលោក ជានិច្ចកាល បដិសេធនូវការយល់ឃើញបែបនេះ ហើយបញ្ជាក់យ៉ាងច្បាស់អំពីសិទ្ធិរបស់គ្រូបង្រៀនក្នុងការចូលរួមធ្វើបាតុកម្ម ដោយសង្កត់ធ្ងន់ថា "សិទ្ធិធ្វើបាតុកម្មអាចមានកំរិតកំហិត ឬហាមឃាត់ជាដាច់ខាតនៅក្នុងមុខងារក្នុងរដ្ឋការ (បុគ្គលិករដ្ឋជាអ្នកដើរតួជាភ្នាក់ងាររបស់អាជ្ញាធររដ្ឋ) ឬនៅក្នុងមុខងារសំខាន់ៗដែលមានកំណត់យ៉ាងច្បាស់លាស់ (ដូចជា កិច្ចការណាដែលអាក់ខាន ហើយខូចប្រយោជន៍សាធារណៈ អាចធ្វើឲ្យ មានគ្រោះថ្នាក់ដល់ជីវិត ឬសុវត្ថិភាព និងសុខភាពរបស់ប្រទេសជាតិទាំងមូល ឬដោយផ្នែក)"។[៣១]

លើសពីនេះទៀត អង្គការពលកម្មពិភពលោកបានបញ្ជាក់បន្ថែមថា ក្រៅពីផលប្រយោជន៍អាជីពរបស់គ្រូបង្រៀន សហជីព "គួរតែមានធនធានសំរាប់ធ្វើការតវ៉ា ជាពិសេសបាតុកម្មដែលមានគោលបំណងរិះគន់គោលនយោបាយសេដ្ឋកិច្ច និងសង្គមកិច្ចរបស់រដ្ឋាភិបាល"។[៣២]

អង្គការពលកម្មពិភពលោកក៏បានប្រឆាំងតវ៉ានឹងការបដិសេធន៍មិនឲ្យគ្រូតវ៉ារួមគ្នាអំពីឋានៈ និងមុខងារជាគ្រូបង្រៀនដែរ។ គណៈកម្មាធិការបានបញ្ជាក់ជំហររបស់ខ្លួនយ៉ាងច្បាស់ថា រាល់ការកំហិតតឹងរឹងទាំងឡាយមិនត្រូវអនុវត្តចំពោះគ្រូបង្រៀនទេ : *"គ្រូមិនបានបំពេញភារកិច្ចជាក់លាក់ដូចបុគ្គលិករដ្ឋដទៃទៀតទេ នៅក្នុងកិច្ចការរដ្ឋបាលរបស់រដ្ឋ ហើយតាមការពិត ការងាររបស់គ្រូក៏ត្រូវបានអនុវត្តនៅក្នុងផ្នែកឯកជនដែរ"*។[៣៣] ភាពមិនស៊ីចង្វាក់គ្នារវាងច្បាប់ក្នុងប្រទេស និងច្បាប់អន្តរជាតិត្រូវបានកាត់បន្ថយ ដូចជា នៅប្រទេសពីលីពីនជាដើម។[៣៤] គណៈកម្មាធិការបានបញ្ជាក់ហើយបញ្ជាក់ទៀតអំពីទស្សនៈរបស់ខ្លួនថា "គ្រូត្រូវតែទទួលបានការការពារដូច បុគ្គលិកដទៃទៀតប្រឆាំងនឹងសកម្មភាពរើសអើងក្នុងការបង្កើតសហជីព។ ប្រសិនជាការការពារនេះមិនត្រូវបាន ធានាដោយច្បាប់ក្នុងស្រុក ដោយហេតុផលណាមួយរបស់តុលាការជាតិ រដ្ឋាភិបាលត្រូវមានវិធីសាស្ត្រផ្សេងទៀត ដើម្បីចាត់វិធានការសមស្របធានាឲ្យបាននូវការការពារបែបនេះចំពោះគ្រូបង្រៀនទាំងនៅក្នុងច្បាប់ និងក្នុងការអនុវត្តជាក់ស្តែង។"[៣៥]

លើសនេះទៀត ការកំហិតចំពោះសហជីពដែលកើតចេញពីការទាមទារឲ្យគ្រូបង្រៀនកែសម្រួលការងារ ឲ្យស៊ីគ្នានឹងគោលនយោបាយរដ្ឋាភិបាល ត្រូវបានចាត់ការដោយអង្គការពលកម្មពិភពលោកដើម្បីធានាថា ច្បាប់អន្តរជាតិការពារ *"ការបង្កើតអង្គការ សហជីពពលកម្ម ដែលមិនស្ថិតនៅក្រោមអាជ្ញាធររដ្ឋ និងគណៈបក្សកាន់អំណាច ហើយបេសកកម្មរបស់ខ្លួនគឺការពារ និងជំរុញផលប្រយោជន៍របស់ខ្លួន និងមិនពង្រឹងប្រព័ន្ធសេដ្ឋកិច្ច និងនយោបាយរបស់គណៈបក្ស ឬប្រទេសទេ។*[៣៦]

---

[31] *Freedom of Association Committee – 272nd Report, Case No. 1503 (Peru), para. 117.*

[32] *Freedom of Association Committee – 304th Report, Case No. 1863 (Guinea), para. 358.*

[33] *Freedom of Association Committee – 302nd Report, Case No. 1820 (Germany), para. 109.*

[34] *Freedom of Association Committee – 278th Report, Case No. 1570 (Philippines), par 162; 281st Report, Case No. 1528 (Germany), para. 19; Report, Case No. 1514 (India), para. 109.*

[35] *Freedom of Association Committee – 300th Report, Case No. 1514 (India), para. 21.*

[36] *Freedom of Association – 286th Report, Case No. 1652 (China), paras. 713-714.*

## ៥.៤. សកម្មភាពរៀនសូត្រ

### ៥.៤.១. ភាសាយានក្នុងការបង្រៀន

ចំណាប់អារម្មណ៍នៃក្របខ័ណ្ឌសកម្មភាពក្រុងដាកាសំរាប់ការអប់រំដោយប្រើប្រាស់ភាសាកំណើតបាន សង្កត់ធ្ងន់លើឧបសគ្គចំបងក្នុងការសិក្សារបស់កុមារ : ប្រសិនជាកុមារមិនយល់ភាសាដែលគេប្រើជាយានសំរាប់បង្រៀនទេ កុមារនឹងពុំមានការចេះដឹងអ្វីទេ ទោះជាគេមករៀនក៏ដោយ។ កតិកាសញ្ញាស្តីពីសិទ្ធិកុមារសង្កត់ធ្ងន់ពីសារៈសំខាន់នៃការប្រើប្រាស់ភាសាយានជាភាសាកំណើតរបស់កុមារក្នុងដំណាក់កាលដំបូងនៃការសិក្សារបស់កុមារ។ ចំណុចនេះក៏មានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសិទ្ធិមនុស្សអន្តរជាតិដែលចែងថា "បុគ្គលម្នាក់ៗត្រូវបានទទួលការធានាដូចគ្នា មានសិទ្ធិរៀនភាសាកំណើតរបស់ខ្លួនបន្ថែមលើភាសាផ្លូវការរបស់ប្រទេស"។[៣៧]

នេះមិនមែនមានន័យថា រដ្ឋាភិបាលមានកាតព្វកិច្ចធានាផ្តល់ការរៀន និងបង្រៀនគ្រប់ភាសាទាំងអស់នៅក្នុងប្រទេសទេ ព្រោះថា រដ្ឋាភិបាលមិនអាចធ្វើបែបនេះបានទេ។ ប៉ុន្តែមានន័យថា រដ្ឋាភិបាលត្រូវតែជួយសម្រួលឲ្យកុមារបានប្រើភាសាកំណើត ជាពិសេសនៅឆ្នាំដំបូងនៃការចូលរៀន។[៣៨]

ច្បាប់សិទ្ធិមនុស្សអន្តរជាតិបញ្ជាក់បន្ថែមពីលើសិទ្ធិរបស់រដ្ឋនីមួយៗដើម្បីកំណត់អំពីភាសាផ្លូវការ និងភាសាយានសំរាប់បង្រៀន។ ដូចបានបង្ហាញនៅក្នុងតារាងទី ១១ សន្ធិសញ្ញាសិទ្ធិមនុស្សទូទៅប្រើប្រាស់ការបង្កើតបែបអវិជ្ជមាននៅពេលដែលកំណត់អត្ថន័យរបស់ពាក្យ "សិទ្ធិ" ដោយការប្រើប្រាស់ពាក្យ ដូចជា "គ្មានអ្នកណាម្នាក់នឹងត្រូវគេបដិសេធមិនឲ្យ ...."។ល។ កតិកាសញ្ញាស្តីពីសិទ្ធិ នយោបាយ និងសិទ្ធិពលរដ្ឋបញ្ជាក់ថា សមាជិកទាំងអស់នៃជនជាតិភាគតិចនឹងមិនត្រូវបានបដិសេធមិនឲ្យប្រើប្រាស់ភាសាឡើយ។ សន្ធិសញ្ញាស្តីពីសិទ្ធិកុមារផ្តល់នូវបញ្ញត្តិប្រហាក់ប្រហែលគ្នាដែរសំរាប់កុមារជនជាតិដើម កុមារជនជាតិភាគតិច។ ដូច្នេះ ការរៀនភាសាក្រៅពីភាសាជាតិពុំមែនជាបន្ទុករបស់រដ្ឋាភិបាលទេ ទាំងផ្នែករៀបចំ និងការ ផ្តល់ហិរញ្ញវត្ថុ។

ទោះបីជាយ៉ាងណាក៏ដោយ ក៏ការហាមឃាត់ជាលក្ខណៈអន្តរជាតិនៃការរើសអើងរួមបញ្ចូលភាសា ស្ថាប័នអប់រំទាំងរដ្ឋ និងឯកជនដែលរក្សា និងពង្រីកភាពសម្បូរបែបនៃភាសា។ ការជ្រើសរើសដែលជាសិទ្ធិរបស់ឪពុកម្តាយមាន

---

**តារាង ១១ : បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ស្តីពីភាសាសិទ្ធិជនជាតិភាគតិច និងជនជាតិដើម**

***អនុសញ្ញាយូណេស្កូប្រឆាំងនឹងការរើសអើង នៅក្នុងការអប់រំ (១៩៦០)***

វាមានសារៈសំខាន់ណាស់ក្នុងការទទួលស្គាល់សិទ្ធិរបស់សមាជិកជនជាតិភាគតិចដើម្បីធានាឲ្យជនជាតិភាគតិចចូលរួមក្នុងសកម្មភាពអប់រំរួមបញ្ចូលទាំងការថែរក្សាសាលា និងប្រើប្រាស់ភាសាកំណើតជនជាតិភាគតិចក្នុងការបង្រៀន (អាស្រ័យលើគោលនយោបាយរបស់ប្រទេសនីមួយៗ) និងធានាថា :

(i) សិទ្ធិនេះមិនត្រូវអនុវត្តក្នុងន័យរារាំងសមាជិកជនជាតិភាគតិចមិនឲ្យយល់ដឹងពីវប្បធម៌ និងភាសាផ្សេងទៀតរបស់សហគមន៍ និងចូលរួមក្នុងសកម្មភាពនានា ឬការរើសអើងពូជសាសន៍នៅក្នុងសង្គម។

(ii) ការចូលរៀននៅក្នុងសាលាបែបនេះគឺធ្វើឡើងដោយការស្ម័គ្រចិត្ត។

***កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ (១៩៦៦)***

នៅក្នុងរដ្ឋដែលមានជនជាតិភាគតិច សាសនា និង ភាសា អ្នកដែលនៅក្នុងក្រុមជនជាតិបែបនេះត្រូវទទួលបានសិទ្ធិដូចពលរដ្ឋទូទៅនៅក្នុងសហគមន៍ រីករាយនឹងវប្បធម៌ គោរព ប្រតិបត្តិតាមសាសនា និងប្រើប្រាស់ភាសារបស់ជនជាតិខ្លួន។

***អនុសញ្ញាអង្គការពលកម្មពិភពលោកស្តីពីជនជាតិដើមនិងជនជាតិភាគតិច (១៩៨៩)***

វិធានការនានាត្រូវរៀបចំឡើងដើម្បីធានាថា រាល់សមាជិកជនជាតិភាគតិច និងជនជាតិដើមទាំងអស់មានឱកាសបានទទួលការអប់រំដូចពលរដ្ឋទូទៅនៅក្នុងសហគមន៍ដែរ។ កម្មវិធី និងសេវាអប់រំសំរាប់ជនជាតិត្រូវតែធ្វើឡើងដោយមានការចូលរួមពីពីជនជាតិ។

លើសពីនេះទៀត រដ្ឋាភិបាលត្រូវតែទទួលស្គាល់សិទ្ធិរបស់ជនជាតិក្នុងការបង្កើតស្ថាប័នអប់រំ និងសម្ភារសិក្សា ប្រសិនជាស្ថាប័នរបស់ជនជាតិឆ្លើយតបទៅនឹងស្តង់ដាជាតិ ដែលរៀបចំដោយអាជ្ញាធរមានសមត្ថភាពត្រឹមត្រូវ។ រដ្ឋាភិបាលត្រូវផ្តល់ធនធានសមរម្យដើម្បីសំរេចគោលបំណងនេះ។

បើអាចធ្វើបាន កុមារជនជាតិត្រូវតែទទួលបានឱកាសរៀនអាន និងរៀនសរសេរភាសាកំណើត ឬភាសាជនជាតិដែលត្រូវប្រើទូទៅនៅក្នុងសហគមន៍។ ប៉ុន្តែ នៅពេលដែលមិនអាចធ្វើបាន អាជ្ញាធរមានសមត្ថភាពត្រូវតែពិគ្រោះយោបល់ជាមួយក្រុមជនជាតិដើម្បីធ្វើការកែសម្រួលឲ្យសំរេចគោលបំណងបែបនេះ។

ត្រូវចាត់វិធានការសមស្របទាំងឡាយដើម្បីធានាឲ្យកុមារជនជាតិមានឱកាសបានរៀនភាសាជាតិឲ្យបានស្ទាត់ជំនាញក្នុងការប្រើភាសាជាតិ។

***អនុសញ្ញាស្តីពីសិទ្ធិកុមារ (១៩៨៩)***

នៅក្នុងរដ្ឋដែលមានជនជាតិភាគតិច ជនជាតិដើម និងសាសនា កុមាររបស់ជនជាតិនោះត្រូវទទួលបានសិទ្ធិដូចពលរដ្ឋទូទៅនៅក្នុងសហគមន៍ គោរពប្រតិបត្តិវប្បធម៌ ជំនឿ សាសនា និងប្រើប្រាស់ភាសា។

---

[37] Wilson, D. - Minority Rights in Education, available at www.right-to-education.org

[38] More information is available at the UNESCO International Mother Language Day, www.unesco.org/education/imld

តួនាទីយ៉ាងសំខាន់ក្នុងបញ្ហានេះ។ សន្ធិសញ្ញាជនជាតិដើម និងជនជាតិភាគតិចរបស់អង្គការពលកម្មពិភពលោក ផ្តល់ការធានាបែបនេះដល់ជនជាតិដើម និងជនជាតិភាគតិច ប៉ុន្តែរហូតមកដល់ពេលនេះមានប្រទេសតែមួយ ចំនួនប៉ុណ្ណោះ ដែលបានផ្តល់សច្ចាប័នចំពោះសន្ធិសញ្ញានេះ។[៣៩]

**សិទ្ធិប្រើប្រាស់ភាសា**

រដ្ឋធម្មនុញ្ញជាតិហាក់ដូចជាមានទំនោរទៅរកភាសាយានតែមួយ ពីព្រោះភាសាយានតែមួយអាចជួយដល់ការកសាងជាតិ។ ឧទាហរណ៍ : រដ្ឋធម្មនុញ្ញនៅឆ្នាំ ១៩៧៤ របស់មីយ៉ាន់ម៉ាចែងថា "ភាសាភូមាជាភាសារួមរបស់ជាតិ។ ភាសារបស់ជនជាតិផ្សេងទៀតក៏អាចបង្រៀនបានដែរ"។ រដ្ឋធម្មនុញ្ញភីលីពីនឆ្នាំ ១៩៨៦ បញ្ជាក់បន្ថែមថា "រដ្ឋាភិបាលនឹងចាត់វិធានការដើម្បីធានានិរន្តរភាពនៃការប្រើប្រាស់ភាសាភីលីពីនសំរាប់ជាយានក្នុងការប្រាស្រ័យទាក់ទងផ្លូវការ និងភាសាយាននៅក្នុងប្រព័ន្ធអប់រំ"។

ប្រទេសមួយចំនួនទៀត ដូចជា ប្រទេសថៃ បានទទួលស្គាល់ថាមានភាសាជនជាតិភាគតិចជាច្រើន និងបញ្ហាលំបាកដែលបង្កឡើង ដោយភាសាខុសគ្នាទាំងនេះ។ "ភាសាគឺជាឧបសគ្គធំធេងក្នុងការសំរេចសិទ្ធិមនុស្សនៅប្រទេសថៃ។ ភាពស្ថិតនៅឆ្ងាយពីគ្នាដែលបណ្តាលមកពីភាសា រួមបញ្ចូលទាំងបញ្ហាផ្សេងទៀតដែលបណ្តាលមកពីឋានៈក្នុងសង្គមដែលគេមិនបានចង់ក្រងជាឯកសារ បង្កើតជាបញ្ហាជាច្រើន នៅក្នុងការផ្តល់ និងរកការងារធ្វើ ដែលស្ត្រី និងកុមារី ដែលមិនមែនជាជនជាតិថៃ ជាអ្នករងគ្រោះ និងទទួលការកេងប្រវ័ញ្ច។[៤០]

ទន្ទឹមនឹងនេះដែរ ប្រទេសមួយចំនួនបានអនុម័តយកភាសាផ្លូវការច្រើន : ប្រទេសសឹង្ហបុរីមានភាសាផ្លូវការ ៤ គឺ ភាសាម៉ាឡេ ចិន តាមីល និង អង់គ្លេស។ ភាសាម៉ាឡេជាភាសាជាតិ និងភាសាអង់គ្លេសជាភាសារដ្ឋបាលទូទៅ។ លក្ខណៈពិសេសនៃប្រព័ន្ធអប់រំសឹង្ហបុរីគឺគោលនយោបាយ ២ ភាសា ដែលធានាថា កុមារម្នាក់ៗរៀន ភាសាអង់គ្លេស និងភាសាកំណើតរបស់ខ្លួនដើម្បីយល់ដឹងពីមរតកវប្បធម៌របស់ខ្លួននៅពេលដែលគេកំពុង តែរៀនជំនាញផ្សេងៗដើម្បីគ្រប់គ្រងសង្គមដែលមានសេដ្ឋកិច្ច ឧស្សាហកម្មជឿនលឿន។[៤១]

---

*39 The Indigenous and Tribal Peoples Convention (No. 169) was adopted in 1989 but as of April 2003 had attained only 17 ratifications, by mostly South American and Western European countries. The only party to this Convention in Asia is Fiji.*

*40 2nd and 3rd periodic reports of Thailand under the Convention on the Elimination of All Forms of Discrimination against Women, U.N. Doc. CEDAW/C/THA/2-3, 1997, para. 41.*

*41 Initial report of Singapore under the Convention on the Rights of the Child, April 2002.*

### ៥.៤.២. ខ្លឹមសារអប់រំ

ច្បាប់សិទ្ធិមនុស្សអន្តរជាតិចាត់ទុកការអប់រំជាទីបញ្ចប់ ឬជាមធ្យោបាយសំរាប់ទទួលបានសិទ្ធិមនុស្សដទៃទៀត។ រាល់សន្ធិសញ្ញាសិទ្ធិមនុស្សទាំងអស់រួមបញ្ចូលការណែនាំជាក់លាក់មួយចំនួនសំរាប់រៀបចំខ្លឹមសារអប់រំ។ បញ្ញត្តិសំខាន់ៗមួយចំនួនត្រូវបានយកមកបង្ហាញឡើង វិញនៅក្នុងតារាងទី១២។ បញ្ញត្តិប្រហាក់ប្រហែលគ្នាបញ្ជាក់ពី ការយល់ស្របគ្នាជាលក្ខណៈអន្តរជាតិ។

**តារាងទី ១២ : តម្រូវការសិទ្ធិមនុស្សសំរាប់ខ្លឹមសារអប់រំ**

***កតិកាសញ្ញាយូណេស្កូប្រឆាំងនឹងការរើសអើងនៅក្នុងការអប់រំ (១៩៦០)***

*ភាគីរដ្ឋនៅក្នុងកតិកាសញ្ញានេះព្រមព្រៀងគ្នាថា : ការអប់រំនឹងនាំទៅដល់ការអភិវឌ្ឍន៏ពេញ លេញនូវបុគ្គលិកលក្ខណៈរបស់មនុស្ស និងការគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាននានា។ វានឹងជំរុញការយោគយល់គ្នា ការអត់អោនគ្នា និងមិត្តភាពក្នុងចំណោមប្រជាជាតិទាំងអស់ ក្រុមជនជាតិ និងសាសនា និងពង្រឹងសកម្មភាពរបស់អង្គការសហប្រជាជាតិដើម្បីថែរក្សាសន្តិភាព។*

***កតិកាសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ចោលនូវការរើសអើងពូជសាសន៍គ្រប់ប្រភេទ (១៩៦៥)***

*ភាគីរដ្ឋនៅក្នុងកតិកាសញ្ញានេះត្រូវចាត់វិធានការបន្ទាន់ និងមានប្រសិទ្ធិភាព ជាពិសេសនៅក្នុងវិស័យអប់រំ វប្បធម៌ និងព័ត៌មាន ដើម្បីប្រយុទ្ធប្រឆាំងការប្រកាន់ពូជសាសន៍ដែលអាចនាំឲ្យមានការរើសអើងជាតិសាសន៍ និងជំរុញការយោគយល់គ្នា អត់ឱនគ្នា និងមិត្តភាពក្នុងបណ្តាប្រទេស និងក្រុមជនជាតិផ្សេងៗ និងផ្សព្វផ្សាយគោលបំណង និងគោលការណ៍ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ សេចក្តីប្រកាសសកលលោកស្តីសិទ្ធិមនុស្ស សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីការលុបបំបាត់ការរើសអើងពូជសាសន៍គ្រប់ប្រភេទ។*

***សន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិវប្បធម៌ សង្គម និងសេដ្ឋកិច្ច (១៩៦៦)***

*ភាគីរដ្ឋនៅក្នុងកតិកាសញ្ញានេះព្រមព្រៀងគ្នាថា : ការអប់រំនឹងនាំទៅដល់ការអភិវឌ្ឍន៏ពេញលេញនូវបុគ្គលិកលក្ខណៈរបស់មនុស្ស និងភាពថ្លៃថ្នូររបស់គេ និងពង្រឹងការគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន។ ពួកគេយល់ស្របគ្នាថា ការអប់រំនឹងធ្វើឲ្យមនុស្សគ្រប់រូបអាចចូលរួម ដោយសកម្មនៅក្នុងសង្គមសេរី និងជំរុញការយោគយល់គ្នា ការអត់អោនគ្នា និងមិត្តភាពក្នុងចំណោមប្រជាជាតិទាំងអស់ក្រុមជនជាតិ និង សាសនា និងពង្រឹងសកម្មភាពរបស់ អង្គការសហប្រជាជាតិដើម្បីថែរក្សាសន្តិភាព។*

***កតិកាសញ្ញាស្តីពីការលុបបំបាត់ការរើសអើងគ្រប់ប្រភេទចំពោះស្ត្រី (១៩៧៩)***

*ភាគីរដ្ឋនឹងចាត់វិធានការសមស្របដើម្បីលុបបំបាត់ការរើសអើងប្រឆាំងស្ត្រីដើម្បីធានាឲ្យស្ត្រីទទួលបានសិទ្ធិស្មើភាពជាមួយបុរសនៅក្នុងវិស័យអប់រំ ជាពិសេសធានាឲ្យពួកស្ត្រីទទួលបានមូលដ្ឋានគ្រឹះ សមភាពរវាងបុរស និងស្ត្រី។ ការលុបបំបាត់ទស្សនៈបែងចែកតួនាទីបុរស និងស្ត្រីនៅគ្រប់កំរិតអប់រំទាំងអស់ ដោយលើកទឹកចិត្តឲ្យមានការអប់រំបញ្ចូលគ្នាទាំងពីរភេទ និងប្រភេទនៃការអប់រំផ្សេងៗទៀតដែលអាចជួយឲ្យសំរេចគោលដៅនេះបាន ជាពិសេស ដោយការពិនិត្យឡើងវិញនូវសៀវភៅមេរៀន និងកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន។*

***សន្ធិសញ្ញាអង្គការពលកម្មពិភពលោកស្តីពីជនជាតិដើម និងជនជាតិភាគតិច (១៩៨៩)***

*ការផ្សព្វផ្សាយចំណេះដឹងនិងជំនាញទូទៅ ដែលជួយកុមារជនជាតិឲ្យបានចូលរួមយ៉ាងពេញលេញ និងស្មើភាពគ្នានៅក្នុងសហគមន៍ និងប្រទេសជាវត្ថុបំណងនៃការអប់រំសំរាប់ជនជាតិភាគតិច និងជនជាតិដើម។ វិធានការអប់រំនឹងត្រូវចាត់តាំងឡើងនៅគ្រប់ផ្នែកទាំងអស់នៃប្រទេស ជាពិសេស ក្នុងចំណោមអ្នកដែលគិតគូរដល់ជនជាតិទាំងនេះ។ ក្នុងន័យនេះ ត្រូវខិតខំប្រឹងប្រែងរៀបចំសៀវភៅប្រវត្តិសាស្ត្រ និងសម្ភារឧបទ្ទេសអប់រំដើម្បីផ្តល់ព័ត៌មានទូលំទូលាយ និងត្រឹមត្រូវអំពីប្រទេស និងវប្បធម៌ ទំនៀមទំលាប់ជនជាតិ។*

***សន្ធិសញ្ញាស្តីពីសិទ្ធិកុមារ (១៩៨៩)***

*ភាគីរដ្ឋទាំងអស់យល់ព្រមព្រៀងគ្នាថា ការអប់រំត្រូវធ្វើឲ្យកុមារ (ក) ការអភិវឌ្ឍបុគ្គលិកលក្ខណៈ កុមារ បញ្ញាស្មារតី និងសមត្ថភាពរាងកាយ យ៉ាងពេញលេញតាមដែលអាចធ្វើបាន។ (ខ) អភិវឌ្ឍការគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន និងសំរាប់ គោលការណ៍ដែលមានចែង នៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។ (គ) ការអភិវឌ្ឍន៏ការគោរពឪពុកម្តាយ អត្តសញ្ញាណវប្បធម៌របស់កុមារ ភាសា និងគុណធម៌ជាតិដែលកុមាររស់នៅ និងប្រទេសដែលជាដើមកំណើតរបស់កុមារ និងសំរាប់ភាពទាន់សម័យដែលខុសពីរបស់ពួកគេ។ (ឃ) ការរៀបចំកុមារសំរាប់ជីវិតដែលមានការទទួលខុសត្រូវនៅក្នុងសង្គមសេរីក្នុងស្មារតីយោគយល់គ្នា សន្តិភាព ការអត់អោន សមភាពនៃភេទទាំងពីរ និងមិត្តភាពក្នុងចំណោមប្រជាជនទាំងអស់ ជនជាតិភាគតិចទាំងអស់ ជាតិ និងក្រុមសាសនា និងជនជាតិដើម។ (ង) ការ អភិវឌ្ឍន៏ឲ្យមានការគោរពស្រលាញ់បរិស្ថានធម្មជាតិ។*

បទបញ្ញត្តិទូនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិទាំងនេះត្រូវបានដឹងឮ និងបញ្ជាក់ច្បាស់តាមរយៈការផ្តល់យោបល់ទូទៅ ដោយអង្គភាពសន្ធិសញ្ញានីមួយៗ។ ឧទាហរណ៍ គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារបាន

[42] *Committe on the Rights of the Child - The aims of education, General comment 1, U.N. Doc. CRC/GC/2001/1 (2001).*

ផ្តល់យោបល់ទូទៅស្តីពីគោលបំណងនៃការអប់រំដែលផ្តល់អនុសាសន៍ឲ្យមានការប្រែក្លាយតម្រូវការសិទ្ធិមនុស្សឲ្យទៅជាកម្មវិធីអប់រំ សៀវភៅសិក្សា និងវិធីសាស្ត្រ រៀន និងបង្រៀន។[42] ការិយាល័យឧត្តមស្នងការដើម្បីសិទ្ធិមនុស្សបានរៀបចំឯកសារសំខាន់ៗមួយចំនួននៅក្នុងទសវត្សរ៍អង្គការសហប្រជាជាតិសំរាប់អប់រំសិទ្ធិមនុស្ស (១៩៩៥-២០០៤)។[43]

នៅថ្នាក់ជាតិ ដំណើរការនេះរួមបញ្ចូលការណែនាំជាផ្លូវការមួយរបស់សិទ្ធិមនុស្សនៅក្នុងកម្មវិធីសិក្សា។ នៅប្រទេសកម្ពុជា *"កម្មវិធីសិក្សាថ្មីរួមបញ្ចូលទាំងសិទ្ធិមនុស្ស បរិស្ថាន ចំណីអាហារ លេខសំគាល់ផ្លូវជាតិ និងសីលធម៌ដោយមានគោលបំណងជួយសិស្សឲ្យទទួលបានចំណេះដឹងកាន់តែស៊ីជំរៅពីទីកន្លែង និងតួនាទី និងដើម្បីធ្វើឲ្យសិស្សមានសារប្រយោជន៍សំរាប់សង្គម"*។[44] នៅប្រទេសពីលីពីន "*បទបញ្ញាប្រតិបត្តិលេខ ២៧ ចុះ ថ្ងៃទី ៤ ខែ កក្កដា ឆ្នាំ ១៩៨៦ ណែនាំក្រសួងអប់រំ វប្បធម៌ និងកីឡាឲ្យបញ្ចូលការសិក្សា និងការយល់ដឹងអំពីសិទ្ធិមនុស្សនៅ្នងកម្មវិធីសិក្សានៅគ្រប់កំរិត និងការបណ្តុះបណ្តាលនៅគ្រប់សាលាទាំងអស់*"។[45]

*ភាពខុសគ្នាដែលគួរឲ្យកត់សំគាល់តែងកើតមានរវាងគុណធម៌* និងការអប់រំសិទ្ធិមនុស្សជាមួយនឹងអ្វីដែលធ្លាប់មាននៅក្នុងសាលាពីមុនមក។ ឧទាហរណ៍មួយនៃទស្សនៈទូលំទូលាយដែលការអប់រំសិទ្ធិមនុស្សព្យាយាមយកមកអនុវត្តឃើញមាននៅប្រទេសសឹង្ហបូរី : *"សារៈសំខាន់នៃគ្រួសារ និងទំនួលខុសត្រូវរបស់ឪពុកម្តាយ និងកូនត្រូវបានយកមកបង្រៀន។ សិស្សបានរៀនអំពីទស្សនៈសីលធម៌ ដូចជា សាមគ្គីភាពគ្រួសារសេចក្តីស្រលាញ់ ការគោរព និងការថែរទាំចាស់ជរា ការប្រាស្រ័យទាក់ទង និងសហការនៅក្នុងគ្រួសារ ចែករំលែកការទទួលខុសត្រូវ និងការថែរក្សាការគោរពស្មោះស្ម័គ្រចំពោះគូស្រករ និងសារៈសំខាន់នៃភាពជាឪពុកម្តាយ"*។[46]

ការពន្យល់បន្ថែមមួយទៀតឃើញនៅក្នុងច្បាប់របស់ប្រទេសមីយ៉ាន់ម៉ាដែលចែងថា *"កុមារទាំងអស់ត្រូវតែគោរពនូវ (១) គោរព និងប្រតិបត្តិតាមច្បាប់ (២) ស្តាប់ដំបូន្មាន និងការប្រៀនប្រដៅរបស់ឪពុកម្តាយ និងអាណាព្យាបាល (៣) ប្រឹងប្រែងរៀនសូត្រដោយសន្តិវិធី និងអនុលោមតាមការណែនាំរបស់គ្រូ (៤) គោរពវិន័យសាលា ការងារនិងសហគមន៍(៥) ថែរក្សាជនជាតិ ភាសា សាសនា វប្បធម៌ និងទំនៀមទំលាប់ប្រពៃណី"*។[47]

## ៥.៤.៣. វិធីសាស្ត្របង្រៀន និងវិន័យសាលា

ជាញឹកញាប់ គេតែងឃើញមានភាពខុសគ្នាយ៉ាងខ្លាំងរវាងការប្តេជ្ញាចិត្តផ្តល់ការអប់រំដែលមានបំណងបង្រៀនកុមារឲ្យមានចំណេះដឹង និងការបង្រៀនជាក់ស្តែងដែលមានលក្ខណៈគ្រាន់តែជួយកុមារឲ្យចងចាំ និងនិយាយឡើងវិញអំពីការពិតនានានៅពេលប្រលងដោយពុំមានការយល់ដឹងអ្វីទេ។ ភាពខុសគ្នាប្រហាក់ប្រហែលគ្នានេះដែរ ក៏ត្រូវបានគេមើលឃើញនៅក្នុងគម្រោងជាច្រើនដែលប្រើប្រាស់វិធីសាស្ត្របង្រៀនបែបសិស្សមជ្ឈមណ្ឌល ឬកុមារមេត្រី និងការប្រើប្រាស់វិធីសាស្ត្របង្រៀនបែបទន្ទេញចាំមាត់ដែលកុមារមួយចំនួនធំកំពុងទទួលយក។

---

*43 The website of the United Nations High Commissioner on Human Rights (www.unhchr.ch) includes a section on human rights education where these documents, and many others, can be found.*

*44 Initial report of Cambodia under the Convention on the Rights of the Child, CRC/C/11/Add.16, 1998.*

*45 Fourteenth periodic report of the Philippines under the Convention against Racial Discrimination, 1997, U.N. Doc. CERD/C7299/Add.12, para. 28.*

*46 Initial report under the Convention on the Rights of the Child, April 2002.*

*47 Initial report under the Convention on the Rights of the Child, 1995, CRC/C/8/Add. 9, paras. 27 and 118.*

ការពន្យល់មួយទាក់ទងនឹងភាពខុសគ្នាយ៉ាងខ្លាំងក្នុងការផ្ដល់ការអប់រំគឺជាចំណុចខ្វះខាតនៃវិស័យអប់រំ ដែលបំរើឲ្យពាក់កណ្ដាលនៃចំនួនប្រជាជនសរុប។ ការពន្យល់មួយទៀត គឺការយកចិត្តទុកដាក់ខ្លាំងលើការសំរេចឲ្យបាននូវស្តង់ដាអប្បបរមាសំរាប់កុមារគ្រប់រូប ដែលយកចិត្តទុកដាក់លើកុមារដែលពុំទាន់បានចូលរៀន ឬសាលាដែលមិនទាន់មានលក្ខណៈដូចគ្នានឹងនិយមន័យនៃពាក្យដែលថា "ការអប់រំដែលមានគុណភាព"។

និន្នាការបច្ចុប្បន្ននៃការចាត់ចំណាត់ថ្នាក់សិស្ស ចំណាត់ថ្នាក់សាលា និងប្រទេសទៅតាមលទ្ធផលប្រលងដែលវាស់ជាលទ្ធផលបរិសវិស័យនោះបានធ្វើឲ្យមានការយល់ច្រឡំដល់ការខិតខំប្រឹងប្រែងដើម្បីទទួលបានលទ្ធផលសិក្សាពិតប្រាកដ។ ដូច្នេះ ការអប់រំដែលផ្អែកលើសិទ្ធិនឹងចង្អុលបង្ហាញអំពីគោលបំណងធំនៃការអប់រំពោលគឺការអភិវឌ្ឍន៍សមត្ថភាសិក្សា និងបន្តការសិក្សាអស់មួយជីវិត។

**ការដាក់ទណ្ឌកម្មលើរាងកាយ និងវិន័យ**

ការអប់រំ និយាយជារួម មានកាតព្វកិច្ចចំពោះមុខជាច្រើនដែលត្រូវបំពេញដើម្បីជំនះដោះស្រាយបញ្ហានៃការបដិសេធសិទ្ធិរបស់កុមារ ដែលកើតមានគ្រប់ជំនាន់ ដូចជាការចាត់ទុកកុមារជាទ្រព្យសម្បត្តិរបស់ឳពុកម្ដាយ ឬក៏ចាត់ទុកដូចជាវត្ថុដែលត្រូវការពារ និងថែទាំ ជាជាងវត្ថុដែលមានសិទ្ធិ។ ខាងក្រោមនេះគឺជាឧទាហរណ៍មកពីប្រទេសកម្ពុជា :

"នៅប្រទេសកម្ពុជា ឳពុកម្ដាយ ឬអាណព្យាបាលជាអ្នកដែលមានដៃធ្ងន់ណាស់ ហើយមិនអនុញ្ញាតឲ្យកូននិយាយច្រើន។ ដោយសារតែការកៀបសង្កត់បែបនេះ កុមារខ្វះសេចក្ដីក្លាហាន មិនហ៊ានផ្ដួចផ្ដើមគំនិត និងការប្ដេជ្ញាចិត្តក្នុងការប្រើប្រាស់សិទ្ធិ ...។ ឳពុកម្ដាយជាច្រើនប្រកាន់នូវទស្សនៈបុរាណថា "ក្មេងត្រូវតែគោរព និងអោនលំទោនចំពោះមនុស្សចាស់" ហើយរៀបចំផ្នត់គំនិតរបស់ក្មេងឲ្យដូចផ្នត់គំនិតរបស់មនុស្សចាស់ចង់បាន ..។ កម្ពុជាមិនទាន់មានច្បាប់ហាមឃាត់មិនឲ្យឳពុកម្ដាយវាយដំកូនទេ"[៤៨]។

វិធីសាស្ត្របង្រៀនដែលប្រើប្រាស់ការគំរាមកំហែង ដូចជាការដាក់ទណ្ឌកម្មរាងកាយដើម្បីឲ្យកុមារប្រតិបត្តិតាម មិនស៊ីគ្នានឹងគោលបំណងនៃការអប់រំទេ។ ដោយហេតុនេះ ដំណើរការដាក់ទណ្ឌកម្មរាងកាយត្រូវទុកឲ្យនៅក្រៅច្បាប់ត្រូវបានគេចាប់ផ្ដើមដោយយកចិត្តទុកដាក់នៅទសវត្សរ៍ ១៩៩០ ដែលនាំឲ្យមានការកែប្រែទូទាំងពិភពលោក។ តារាងទី ១៣ មានចុះបញ្ជីប្រទេស ដែលមានច្បាប់ហាមឃាត់មិនឲ្យមានការដាក់ទណ្ឌកម្មរាងកាយនៅក្នុងសាលា។ តារាងនេះក៏បង្ហាញពីការវិវត្តយ៉ាងលឿននៃការកែប្រែនេះនៅទូទាំងពិភពលោក។

**តារាងទី ១៣ : ប្រទេសដែលមានច្បាប់ហាមឃាត់មិនឲ្យមានការដាក់ទណ្ឌកម្មរាងកាយនៅក្នុងសាលា**

Albania, Andorra, Armenia, Austria, Azerbaijan, Bahrain, Belarus, Belgium, Bosnia and Herzegovina, Bulgaria, Burkina Faso, Cameroon, China, Colombia, Congo, Costa Rica, Croatia, Cyprus, Czech Republic, Denmark, Dominican Republic, Egypt, El Salvador, Eritrea, Estonia, Ethiopia, Fiji, Finland, France, Georgia, Germany, Greece, Guinea-Bissau, Honduras, Hong Kong, Hungary, Iceland, Indonesia, Iran, Iraq, Ireland, Israel, Italy, Japan, Kazakhstan, Kenya, Latvia, Liechtenstein, Lithuania, Luxembourg, Macedonia, Malawi, Maldives, Malta, Mauritius, Moldova, Monaco, Mongolia, Namibia, Nether-lands, New Zealand, Norway, Oman, Philippines, Poland, Portugal, Qatar, Republic of Korea, Russia, Samoa, San Marino, Serbia, Slovakia, Slovenia, South Africa, Spain, Sri Lanka, Suriname, Sweden, Switzerland, Taiwan, Thailand, Trinidad and Tobago, Turkey, Uganda, Ukraine, United Kingdom, Uzbekistan, Zambia, Zimbabwe

**Source: www.endcorporalpunishment.org January 2003**

48 *Initial report under the Convention on the Rights of the Child, CRC/C/11/Add. 16, 1998*